ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំព្រហ្មទណ្ឌ
លេខ:៨៣២/១៨-១០-២០១០
សាលដីកា
លេខ:៩៩ ក្រ.វ.ក/០៦-១២-២០១២

តាងនាមប្រជារាស្ត្រខ្មែរ
សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រុមប្រឹក្សា

លោក [redacted] ចៅក្រុមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍រឿងព្រហ្មទណ្ឌលេខ:៨៣២ ចុះថ្ងៃទី១៨-១០-២០១០ រវាង:

១-ជនជាប់ចោទឈ្មោះ[redacted] សារ៉ែន ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរមុខរបរកសិករ ទីកន្លែងកំណើតនិងទីលំនៅសព្វថ្ងៃ[redacted] ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ[redacted] (រ) ទោសពីមុនគ្មាន ។ឃុំខ្លួនថ្ងៃ០៤-០៤-២០០៩(ដើមបណ្តឹងឧទ្ធរណ៍)

មេធាវីលោក[redacted] សុផង់

២-ជនជាប់ចោទឈ្មោះ[redacted] ចាន់ឌី ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ

៣-ជនជាប់ចោទឈ្មោះ[redacted] លីណា ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ

៤-ជនជាប់ចោទឈ្មោះ[redacted] ពៅ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ

ត្រូវចោទពីបទ:ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តិនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌ ដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះឈ្មោះ ណុយ សារិទ្ធ ភេទប្រុស អាយុ៣១ឆ្នាំទីលំនៅសព្វថ្ងៃភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

**៦រឿងហេតុមានដូចតទៅ:**

តាមពាក្យបណ្តឹងចុះថ្ងៃទី១៤-១១-២០០៧ របស់ឈ្មោះ[redacted] សារិទ្ធ ប្តឹងពីឈ្មោះច្រឹក [redacted] ឈ្មោះ[redacted] ចាន់ឌី ឈ្មោះ[redacted]ពៅ ឈ្មោះ[redacted]ដារ៉ា និងឈ្មោះ[redacted] លីណា ដោយសំអាងថា កាលពីថ្ងៃទី១១-/





Scanned with CamScanner

១១-២០០៧ វេលាម៉ោង២១,១០នាទី ពេលខ្លួនមកពីមើលទូរទស្សន៍ដើរមកផ្ទះវិញ ស្រាប់តែឈ្មោះដូចខាងលើបានហៅខ្លួនឈប់និងសួរ ហើយខ្លួនបានដើរពីរ បីជំហាន ស្រាប់តែពួកវាលួចកាប់ចំក្បាលខ្លួនមួយកាំបិតរបួស២០ស.ម និងមួយកាំបិតទៀតចំខ្នងខាងស្តាំរបួស១៦ស.ម បណ្តាលឲ្យរបួសធ្ងន់ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៣២ "វ/ហ" ចុះថ្ងៃទី៣០-៧-២០១០ របស់សាលាដំបូង ខេត្តកណ្តាល ដែលមានខ្លឹមសារដូចតទៅ៖

១-សម្រេចផ្តន្ទាទោសលើឈ្មោះ [redacted] សាវ៉ែន ភេទប្រុសសញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១០ឆ្នាំ(ដប់)ឆ្នាំ គិតពីថ្ងៃឃុំខ្លួន(០៨-០៨-២០០៩) ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា តាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋអំពើនេះ ប្រព្រឹត្តិកាលពីថ្ងៃទី១១ -១១-២០០៧ នៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

២-សម្រេចផ្តន្ទាទោសលើឈ្មោះ [redacted] ចាន់ឌី ភេទប្រុស សញ្ជាតិខ្មែរជនជាប់ចោទឈ្មោះ [redacted] ពៅ ភេទប្រុសសញ្ជាតិខ្មែរ,ឈ្មោះ [redacted] លីណា ភេទប្រុស សញ្ជាតិខ្មែរដាក់ពន្ធនាគារកំណត់១០ឆ្នាំ(ដប់)ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា តាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ អំពើនេះប្រព្រឹត្តកាលពីថ្ងៃទី១១-១១-២០០៧ នៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

៣-បង្គាប់ឲ្យពិរុទ្ធជនឈ្មោះ [redacted] ចាន់ឌី , [redacted] សាវ៉ែន , [redacted] លីណា និងពិរុទ្ធជនឈ្មោះ [redacted] ពៅ រួមគ្នាសងជាសាមគ្គីភាព ទៅដើមបណ្តឹងរដ្ឋប្បវេណីនូវប្រាក់ថ្លៃព្យាបាលចំនួន១.៥០០,០០០រ(មួយលាន-ប្រាំសែន) រៀល និងសំណងជម្ងឺចិត្តចំនួន៥.០០០.០០០រ(ប្រាំលាន)រៀល។

៤-បង្គាប់ឲ្យចាប់ខ្លួនពិរុទ្ធជនឈ្មោះ [redacted] ចាន់ឌី, [redacted] លីណា, [redacted] ពៅ និងបញ្ជាដល់កងកំលាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់និងនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគារ និងបញ្ជាដល់ប្រធានពន្ធនាគារឲ្យទទួលនិងឃុំខ្លួនបុគ្គលនោះ ។ ប្រធានពន្ធនាគារដែលបានទទួលពិរុទ្ធជន ត្រូវតែនាំពិរុទ្ធជននោះទៅបង្ហាញខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត នៅចំពោះមុខព្រះរាជអាជ្ញា។

៥-សាលក្រមនេះ បានបំពេញកិច្ចពិភាក្សាដេញដោលប្រព្រឹត្តទៅនៅក្នុងពេលសវនាការ ជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សាវ៉ែន ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]-សារិទ្ធ និងកំបាំងមុខជនជាប់ចោទ [redacted] ចាន់ឌី, [redacted] ពៅ, [redacted] លីណា ប្រកាសជាសាធារណៈ បើកផ្លូវប្តឹងទាស់រយៈពេល១៥ថ្ងៃតាមមាត្រា ៣៦៨ ប្តឹងឧទ្ធរណ៍រយៈពេល១ខែតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥-០៨-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] សាវ៉ែន សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខលេខ៣២ "វ/ហ" ចុះថ្ងៃទី៣០-៧-២០១០ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី២៧-៩-២០១១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

## __នាពេលសវនាការ__

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ណុយ សារិទ្ធ (អវត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] សាវ៉ែន បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុខ្លួនមិនបានប្រព្រឹត្តទេ ខ្លួនមិនស្គាល់ឈ្មោះ [redacted] ចាន់ឌី, [redacted] ពៅ, [redacted] លីណានិងជនរងគ្រោះទេ ហើយថ្ងៃនោះខ្លួនកំពុងបាស់នៅវត្តក្បាំជាមួយបងប្អូនរបស់ខ្លួន ។ ផ្ទះខ្លួននៅឆ្ងាយពីកន្លែងកើតហេតុប្រហែលមួយគីឡូម៉ែត្រ និងឆ្ងាយពីផ្ទះជនរងគ្រោះប្រហែលបួនគីឡូម៉ែត្រហើយគេចាប់ខ្លួននៅផ្ទះ ក្រោយពេលកើតហេតុប្រហែលបីឆ្នាំ ។ សំណូមពរសុំតុលាការមេត្តាលើកលែងចោទប្រកាន់។

តំណាងមហាអយ្យការផ្តល់សេចក្តីសន្និដ្ឋាន៖

-បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទត្រឹមត្រូវតាមទំរង់ច្បាប់



Scanned with CamScanner

-ជនជាប់ចោទបដិសេធ ប៉ុន្តែចម្លើយសាក្សីថាជនជាប់ចោទបានកាប់លើជនរងគ្រោះ សុំក្រុមប្រឹក្សាពិចារណានិងសំរេចតាមច្បាប់។

មេធាវីថ្លែងសេចក្តីសន្និដ្ឋាន:

រឿងនេះអង្គហេតុកើតពីឆ្នាំ២០០៧ ចាប់ខ្លួនជនជាប់ចោទឆ្នាំ២០០៩ ហើយសាក្សីមានច្រើនខ្លះថាជនជាប់ចោទជាអ្នកកាប់ ឯសាក្សីឈ្មោះយ៉ង់ ស៊ីណាថាមានជនជាប់ចោទដល់៥នាក់ហើយឈ្មោះ [redacted] ចាន់នីជាអ្នកចាក់លើជនរងគ្រោះ គឺសាក្សីឆ្លើយខុសៗគ្នា ។ បើកូនក្តីខ្លួនមានចេតនាកាប់គេគាត់រត់ហើយ តែគាត់មិនបានប្រព្រឹត្ត ។ សូមក្រុមប្រឹក្សាឲ្យកូនក្តីរួចផុតពីបទចោទតាមមាត្រា៣៨នៃរដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមព្រហ្មទណ្ឌ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាល្អិតល្អន់ត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥-០៨-២០១០ របស់ជនជាប់ចោទ ឈ្មោះ [redacted] សារ៉ៃ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៣២ វ/ហ ចុះថ្ងៃទី៣០-០៧-២០១០ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-ជនជាប់ចោទបានឆ្លើយបដិសេធការចោទប្រកាន់ប៉ុន្តែមានសាក្សីឈ្មោះ [redacted] ស៊ីណា បានឃើញជនជាប់ចោទកាប់ជនរងគ្រោះចំនួនពីរដង ដោយមិនដឹងមូលហេតុ ។ តាមលិខិតពេទ្យបានបញ្ជាក់ថាជនរងគ្រោះមានស្នាមរបួសត្រង់ក្បាល។

៣-ជនជាប់ចោទកាប់ជនរងគ្រោះរបួសត្រង់ក្បាលនិងខ្នង គ្មានចេតនាសម្លាប់ជនរងគ្រោះទេ ប៉ុន្តែមានចេតនាបង្ករបួសលើជនរងគ្រោះ គប្បីកែប្រែតាមបទចោទឡើងវិញ ។

៤-សាលក្រមព្រហ្មទណ្ឌលេខ៣២ វ/ហ ចុះថ្ងៃទី៣០-០៧-២០១០ របស់សាលាដំបូងខេត្តកណ្តាលបានសម្រេចត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមទុកជាបានការ លើកលែងតែចំណុចដូចបានសំអាងហេតុទី៣ ខាងលើដែលត្រូវកែតម្រូវឡើងវិញ។

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥-០៨-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉េន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-កែប្រែបទចោទប្រកាន់ពីបទ ប៉ុនប៉ងមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១១-១១-២០០៧ តាមបញ្ញត្តិមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកជាបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ ប្រព្រឹត្តនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១១-១១-២០០៧ តាមមាត្រា២១៧ និង២១៨ នៃក្រមព្រហ្មទណ្ឌ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៣២ វ/ហ ចុះថ្ងៃទី៣០-០៧-២០១០ របស់សាលាដំបូងខេត្តកណ្តាលទុកជាបានការ លើកលែងតែចំណុចទី១ នៃសេចក្តីសម្រេចត្រង់ផ្តន្ទាទោសឈ្មោះ [redacted] សារ៉េន



Scanned with CamScanner

ដាក់ពន្ធនាគារកំណត់១០ឆ្នាំ ត្រូវកែប្រែជា *ផ្តន្ទាទោសឈ្មោះ [redacted] សាវ៉ន ដាក់ពន្ធនាគារកំណត់៤ឆ្នាំ (បួនឆ្នាំគត់)*។ ចំណុចដទៃទៀតនៅរក្សាទុកជាបានការដដែល ។

៤-បន្តឃុំខ្លួនជនជាប់ចោទខាងលើតាមនីតិវិធី ។

សាលដីកានេះជំនុំជំរះ ចំពោះមុខមេធាវីការពារជនជាប់ចោទ ជនជាប់ចោទឈ្មោះ [redacted] សាវ៉ន និង ប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១២ បើកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់កំណត់ ។/

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

---

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ [illegible] ឆ្នាំ ២០១៤

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner